ស៊ីសុផុន ហុងសេង ស្ព័តវែរ ឯ.ក
SISOPHON HONGSENG SPORTSWEARS CO., LTD.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀង
# ព្យួរកិច្ចសន្យាការងារ

កិច្ចព្រមព្រៀងនេះត្រូវបានធ្វើឡើងនៅ **ក្រុមហ៊ុនស៊ីសុផុន ហុងសេង ស្ព័តវែរ ឯ.ក** ដែលមានអាសយដ្ឋាន នៅផ្លូវ ៧មករា ភូមិដីឡូត៍ សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ប្រទេសកម្ពុជា ។

រវាង

**ក្រុមហ៊ុនស៊ីសុផុន ហុងសេង ស្ព័តវែរ ឯ.ក** ដោយ **លោក ក្រៃវុធ ប៉ែនញឹម** ជាអ្នកដែលមានសិទ្ធិក្នុងការសម្រេចនៅក្នុងការិយាល័យក្រុមហ៊ុន ដែលមានទីតាំងស្ថិតនៅលើផ្លូវ ៧មករា ភូមិដីឡូត៍ សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ប្រទេសកម្ពុជា លើការចែងសេចក្តីប្រកាសនិងកិច្ចព្រមព្រៀងនេះ តាងដោយពាក្យថា **ភាគី "ក"** ។

ជាមួយ

បុគ្គលិក កម្មករនិយោជិតដែលបម្រើការងារនៅក្នុងរោងចក្រកាត់ដេរសំលៀកបំពាក់ **ស៊ីសុផុន ហុងសេង ស្ព័តវែរ ឯ.ក** ដែលមានតំណាងកម្មករគ្រប់ផ្នែក និងជាអ្នកតំណាងអោយបុគ្គលិក កម្មករនិយោជិតទាំងអស់ ក្នុងការសម្រេច ដឹងលឺ និងឯកភាពលើសេចក្តីប្រកាសនិងកិច្ចព្រមព្រៀងនេះ តាងដោយពាក្យថា **ភាគី "ខ"** ។

**ភាគីទាំងពីរបានព្រមព្រៀងគ្នាជាមួយកិច្ចព្រមព្រៀង ព្យួរកិច្ចសន្យាការងារដែលមានការកំណត់ដូចតទៅ៖**

**មាត្រា១.** យោងតាមមាត្រា៧១ និងមាត្រា៧២ នៃច្បាប់ស្តីពីការងារ របស់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២.** ដោយភាគី "ក" ពុំមានការបញ្ជាទិញពីអតិថិជន និងមិនមានការងារសម្រាប់ផលិតបន្តទៀត ដោយសារតែរងផលប៉ះពាល់មកពីបញ្ហាជំងឺកូវីដ-១៩ បានធ្វើអោយ ភាគី "ក" ជួបប្រទះនូវបញ្ហាសេដ្ឋកិច្ច ភាគី "ក" សម្រេចអនុវត្តការព្យួរកិច្ចសន្យាការងារ ភាគី "ខ" បណ្តោះអាសន្ន ដោយយោងតាមមាត្រា៧១ (ចំនុចទី ១១) និងមាត្រា៧២ នៃច្បាប់ស្តីពីការងារ របស់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៣.** ភាគី "ក" ស្នើសុំព្យួរកិច្ចសន្យាការងារ ភាគី "ខ" ចំនួន ២១នាក់ (ស្រី ១០នាក់) ក្នុងចំណោមភាគី "ខ" សរុបចំនួន ២០៨នាក់ (ស្រី ១៦៣នាក់) រយៈពេល ១០ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ ២០២០ រហូតដល់ថ្ងៃទី០២ ខែសីហា ឆ្នាំ២០២០។

**មាត្រា៤.** ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារនេះ ភាគី "ក" បានធ្វើការព្រមព្រៀងផ្តល់ប្រាក់ឧបត្ថម្ភជូន ភាគី "ខ" ចំនួន **១០** ដុល្លារអាមេរិកក្នុងរយៈពេល ១០ ថ្ងៃ (យោងទៅតាមសេចក្តីណែនាំនិងប្រកាសលេខ **០៤៥/២០ ក.ប/ស.ណ.ន.ខ.ល** ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២០ ស្តីពីការព្យួរកិច្ចសន្យាការងារ និងការផ្អាកបង់ភាគទាន ប.ស.ស. សម្រាប់រោងចក្រ សហគ្រាស ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារជំងឺកូវីដ-១៩) ។

**មាត្រា៥.** ការទូទាត់ប្រាក់ខែរបស់ ភាគី "ខ" គឺ ភាគី "ក" នឹងផ្ទេរប្រាក់ទៅអោយតាមលេខបញ្ជី AMK តាមធម្មតា ។

អាសយដ្ឋាន៖ ផ្លូវ៧មករា ភូមិដីឡូត៍ សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ
ที่อยู่: 7 มกรา หมู่บ้านเดยโล อำเภอตึกถลา เมืองศรี โสภณ จังหวัดบันเตียเมียนเจย
ទូរស័ព្ទលេខ៖ ០៨៥ ៥៧៩ ០៩១ / ០៩៣ ៣៩៩ ៣៤២
โทรศัพท์: 085 579 091 / 093 399 342

កិច្ចព្រមព្រៀងនេះត្រូវបានធ្វើឡើងយោងទៅតាមប្រកាសនិងតាមច្បាប់ស្តីពីការងារ នៃព្រះរាជាណាចក្រកម្ពុជាទាំងស្រុង និងផ្អែកទៅលើខ្លឹមសារដែលទាក់ទងទៅនឹងបញ្ហាសេដ្ឋកិច្ចទូទាំងសាកលលោកនាពេលបច្ចុប្បន្ន ដែលភាគីទាំងពីរបានអាន និងយល់អំពីការកំណត់ដែលបានចែងនៅក្នុងកិច្ចព្រមព្រៀងខាងលើ ដោយបានអាន និងឃើញថាត្រឹមត្រូវ ។

ដូច្នេះស្នើសុំអោយចុះហត្ថលេខានៅចំពោះមុខអ្នកគ្រប់គ្រងទូទៅ និងតំណាងបុគ្គលិក កម្មករនិយោជិត ដើម្បីទទួលដឹងលឺ និងអនុវត្តកិច្ចព្រមព្រៀងនេះចាប់ពេលនេះតទៅ

ធ្វើនៅបន្ទាយមានជ័យ, ថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០២០

**អ្នកគ្រប់គ្រងនៅក្រុមហ៊ុនសុីសុផុន ហុងសេង ស្ព័តវែរ ៦.ក**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ស៊ីសុផុន ហុង សេង ស្ព័តវែរ ៦.ក SISOPHON HONG SENG SPORTSWEAR CO., LTD KINGDOM OF CAMBODIA

ហត្ថលេខា........................................................................ ភាគី "ក"

**(លោក ក្រែវុធ្ឍ ប៉ែនព្លឹម)**

**បុគ្គលិក កម្មករនិយោជិតនៅក្នុងក្រុមហ៊ុនសុីសុផុន ហុងសេង ស្ព័តវែរ ៦.ក**

ហត្ថលេខាភាគី "ខ"

អាសយដ្ឋានៈ ផ្លូវ៧មករា ភូមិជីឡូត៍ សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ
ที่อยู่: 7 มกรา หมู่บ้านเคยโล อำเภอตึกถลา เมืองศรี โสภณ จังหวัดบันเตียเมียนเจย

ទូរស័ព្ទលេខៈ ០៨៥ ៥៧៩ ០៩១ / ០៩៣ ៣៩៩ ៣៤២
โทรศัพท์: 085 579 091 / 093 399 342